# ជំនួយ និងព័ត៌មានហិរញ្ញវត្ថុរបស់អតិថិជនអ្នកប្រើប្រាស់ COVID -19

## ការពារខ្លួនអ្នកក្នុងផ្នែកហិរញ្ញវត្ថុ

https://www.consumerfinance.gov/about-us/blog/protect-yourself-financially-from-impact-of-coronavirus/

## ជំនួយផ្នែកអ៊ីប៉ូតែកសម្រាប់ពលរដ្ឋវ៉ាស៊ីងតោន

- ប្រសិនបើអ្នកមិនអាចធ្វើការបង់ទូទាត់កម្ចីផ្ទះ (អ៊ីប៉ូតែក) របស់អ្នកបានទេ ឬអាចបង់ទូទាត់បានតែមួយចំណែក សូមទាក់ទងក្រុមហ៊ុនផ្តល់សេវាកម្មកម្ចីរបស់អ្នកភ្លាម។
- **ការផ្តល់ប្រឹក្សា និងជំនួយភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងគឺមានផ្តល់ជូនពលរដ្ឋវ៉ាស៊ីងតោន** ដោយមិនគិតដល់ថានរណាមាន ឬផ្តល់សេវាកម្មកម្ចីនោះឡើយ។ ម្ចាស់ផ្ទះអាចហៅទូរស័ព្ទទៅកាន់លេខទូរស័ព្ទឥតគិតថ្លៃរបស់ DFI តាមលេខ **1-877-RING-DFI (746-4334)** ដើម្បីទទួលបានជំនួយនៅក្នុងការទាក់ទងអ្នកផ្តល់សេវាកម្មអ៊ីប៉ូតែករបស់ពួកគេ និងដើម្បីស្វែងយល់បន្ថែមអំពីជម្រើស។ ដើម្បីធ្វើការជាមួយអ្នកផ្តល់ប្រឹក្សាផ្នែកផ្ទះសម្បែង សូមហៅទូរស័ព្ទទៅកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍នៃភាពជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែងនៃរដ្ឋវ៉ាស៊ីងតោនតាមលេខ **1.877.894.HOME (4663)**។ សេវាកម្មអ្នកបកប្រែគឺមានតាមរយៈលេខទាំងពីរខ្សែនេះ។

**ច្បាប់ស្តីអំពីជំនួយ ជំនួយសង្គ្រោះ និងសន្តិសុខសេដ្ឋកិច្ចដោយសារវីរុសកូរ៉ូណា (CARES)** ដាក់ឲ្យប្រើប្រាស់នូវការការពារចំនួនពីរ <u>សម្រាប់ម្ចាស់ផ្ទះដែលមានកម្ចីផ្ទះដែលគាំទ្រជាលក្ខណៈសហព័ន្ធ</u>៖

1. អ្នកផ្តល់កម្ចីរបស់អ្នក ឬអ្នកផ្តល់សេវាកម្មកម្ចីរបស់អ្នកអាចនឹងមិនរឹបអូសយកទ្រព្យបញ្ចាំពីអ្នកឡើយ រហូតដល់ក្រោយថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020 - សូមចូលមើល www.hud.gov សម្រាប់បច្ចុប្បន្នភាព។ ជាពិសេសនោះ ច្បាប់ CARES ហាមប្រាមអ្នកផ្តល់កម្ចី និងអ្នកផ្តល់សេវាកម្មកម្ចីមិនឲ្យចាប់ផ្តើមការរឹបអូសទ្រព្យបញ្ចាំតាមផ្នែកតុលាការ ឬមិនតាមផ្នែកតុលាការប្រឆាំងនឹងអ្នក ឬមិនឲ្យសម្រេចបញ្ចប់ស្ថាពរនូវការវិនិច្ឆ័យការរឹបអូសទ្រព្យបញ្ចាំ ឬការលក់ក្នុងអំឡុងពេលនេះឡើយ។ (**ការរឹបអូសទ្រព្យបញ្ចាំ** គឺជា ដំណើរការផ្លូវច្បាប់ដែលក្នុងនោះម្ចាស់ផ្តល់កម្ចីគ្រប់គ្រងលើអចលនទ្រព្យ

បណ្តេញម្ចាស់ផ្ទះចេញ ហើយលក់ផ្ទះក្រោយពីម្ចាស់ផ្ទះមិនអាចធ្វើការបង់ទូទាត់ពេញគ្រប់ចំនួន បាន)។

2. ប្រសិនបើអ្នកជួបប្រទះនូវភាពលំបាកផ្នែកហិរញ្ញវត្ថុដោយសាររោគរាតត្បាតវីរុសកូរ៉ូណាជាសាកល អ្នកមានសិទ្ធិស្នើសុំការអត់ឱនអនុគ្រោះបានរហូតដល់រយៈពេល 180 ថ្ងៃ។ អ្នកក៏មានសិទ្ធិផងដែរក្នុងការស្នើសុំការពន្យារពេលមួយដងទៀតសម្រាប់ការអត់ឱនអនុគ្រោះមួយផ្សេងទៀតបានរហូតដល់ 180 ថ្ងៃផងដែរ។ អ្នកត្រូវតែទាក់ទងអ្នកផ្តល់សេវាកម្មកម្ចីរបស់អ្នកដើម្បីស្នើសុំការអត់ឱនអនុគ្រោះនេះ។ នឹងមិនមានថ្លៃឈ្នួលបន្ថែម ការផាកពិន័យ ឬការប្រាក់បន្ថែម (ហួសពីចំនួនតាមកាលវិភាគ) ដែលបានបន្ថែមទៅក្នុងគណនីរបស់អ្នកឡើយ។ **ការអត់ឱនអនុគ្រោះ** គឺជាពេលដែលអ្នកផ្តល់សេវាកម្មអ៊ីប៉ូតែករបស់អ្នក គឺក្រុមហ៊ុនដែលធ្វើរបាយការណ៍កម្ចីរបស់អ្នក និងគ្រប់គ្រងកម្ចីរបស់អ្នក ឬអ្នកផ្តល់កម្ចីអនុញ្ញាតឲ្យអ្នកផ្អាក ឬបន្ថយការបង់ទូទាត់របស់អ្នកសម្រាប់រយៈពេលមានកំណត់។ ការអត់ឱនអនុគ្រោះមិនលុបចោលអ្វីដែលអ្នកជំពាក់នោះទេ។ អ្នកនឹងត្រូវតែសងការទូទាត់ដែលខកខាន ឬដែលបានកាត់បន្ថយនៅពេលអនាគត។

## <u>ការឆបោក</u>

**ការឆបោកក្នុងការវិនិយោគដោយសារ COVID-19៖** មុនធ្វើការសម្រេចចិត្តលើការវិនិយោគធំៗណាមួយ អ្នកវិនិយោគគួរតែស្រាវជ្រាវ និងផ្ទៀងផ្ទាត់ថាពួកគេកំពុងធ្វើការជាមួយអ្នកអាជីពហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ។ សូមហៅទូរស័ព្ទទៅកាន់លេខ 877-RING-DFI (746-4334) សម្រាប់ជំនួយ។

### គន្លឹះសម្រាប់ចៀសវាងការបោកប្រាស់ (sic)

- ស្ថាប័នរដ្ឋាភិបាលនឹងមិនហៅទូរស័ព្ទ ឬផ្ញើសារជាអក្សរទៅអ្នកអំពីអត្ថប្រយោជន៍ ឬលុយទេ ហើយពួកគេនឹងមិនស្នើទៅអ្នកសុំឲ្យដាក់ប្រាក់ ថ្លៃឈ្នួល ឬការបង់ទូទាត់ដទៃផ្សេងទៀតដើម្បីទទួលបានអត្ថប្រយោជន៍របស់អ្នកនោះទេ។
- ស្ថាប័នរដ្ឋាភិបាលនឹងមិនស្នើទៅអ្នកសុំលេខរបបសន្តិសុខសង្គមរបស់អ្នក លេខគណនីធនាគាររបស់អ្នក ឬលេខប័ណ្ណឥណទានរបស់អ្នកឡើយ។

- សូមប្រយ័ត្ននឹងអ៊ីមែល ការហៅទូរស័ព្ទ និងសារជាអក្សរមកពីប្រភពដែលអ្នកមិនស្គាល់។

## វីរុសកូរ៉ូណា៖ ព័ត៌មានសម្រាប់អ្នកខ្ចីកម្ចីជាសិស្សនិស្សិត

សម្រាប់ជំនួយជាមួយនឹងកម្ចីសម្រាប់សិស្សនិស្សិតរបស់អ្នក សូមទាក់ទង **អ្នកគាំពារកម្ចីសិស្សនិស្សិតរដ្ឋវ៉ាស៊ីងតោន** នៅ Washington Student Achievement Council តាមលេខ loanadvocate@wsac.wa.gov ឬហៅទូរស័ព្ទទៅកាន់ DFI តាមលេខ 877—746-4334 ដើម្បីនិយាយជាមួយសមាជិកនៃក្រុមការងារអ្នកផ្តល់សេវាកម្មកម្ចីអប់រំរបស់សិស្សនិស្សិតយើង។